




សេចក្តីជូនដំណឹងរបស់ MassDEP អំពីការមិនរើសអើង

ក្រសួងការពារបរិស្ថាននៃរដ្ឋ Massachusetts (MassDEP) បើកដំណើរការកម្មវិធីសេវាកម្ម និងសកម្មភាពរបស់ខ្លួនដោយអនុលោមតាមច្បាប់ចូលជាធរមានស្តីពីការមិនការរើសអើង។ MassDEP អនុលោមតាមច្បាប់ និងបទប្បញ្ញត្តិរបស់សហព័ន្ធនិងរដ្ឋដែលចូលជាធរមាន ហើយនឹងមិនអនុញ្ញាតឲ្យមានការរើសអើង ការបំភិតបំភ័យ ការគំរាមកំហែង ការបង្ខិតបង្ខំ ឬការសងសឹកទៅលើបុគ្គល ឬក្រុមណាមួយឡើយ។

**ច្បាប់សហព័ន្ធ - ចំណងជើង VI /ការការពារដោយគ្មានការរើសអើង**

MassDEP អនុលោមតាមចំណងជើង VI នៃច្បាប់ស្តីពីសិទ្ធិស៊ីវិលឆ្នាំ 1964 និងលក្ខន្តិកៈ និងបទប្បញ្ញត្តិសហព័ន្ធផ្សេងទៀតដែលចូលជាធរមាន[1] ក្នុងការអនុវត្តកម្មវិធីរបស់ខ្លួន។ ចំណងជើង VI ចែងពីការហាមឃាត់ការរើសអើងនៅក្នុងកម្មវិធីផ្តល់ជំនួយដោយសហព័ន្ធ ហើយចែងតម្រូវថា គ្មានជនណាម្នាក់នៅសហរដ្ឋអាមេរិក ផ្អែកលើពូជសាសន៍ ពណ៌សម្បុរ ឬដើមកំណើតជាតិ (រួមទាំងជំនាញភាសាអង់គ្លេសមានកម្រិត) ត្រូវបានបដិសេធមិនឲ្យចូលរួមក្នុង ត្រូវបានបដិសេធផ្តល់អត្ថប្រយោជន៍ ឬត្រូវទទួលរងការរើសអើងក្រោមកម្មវិធី ឬសកម្មភាពណាមួយដែលទទួលបានជំនួយហិរញ្ញវត្ថុពីរដ្ឋាភិបាលសហព័ន្ធឡើយ។

**ច្បាប់រដ្ឋ –ការការពារដោយគ្មានការរើសអើង**

MassDEP អនុលោមតាមបទបញ្ជាប្រតិបត្តិរបស់អភិបាលលេខ 526 ផ្នែកទី 4 ដែលតម្រូវឱ្យគ្រប់កម្មវិធី សកម្មភាព និងសេវាកម្មទាំងអស់ដែលបានផ្តល់ជូន អនុវត្ត ទទួលបានអាជ្ញាប័ណ្ណ ផ្តល់ការអនុញ្ញាត ផ្តល់មូលនិធិ ធ្វើនិយ័តកម្ម ឬធ្វើកិច្ចសន្យាសម្រាប់ និងដោយរដ្ឋ ដើម្បីធ្វើដោយគ្មានការរើសអើងខុសច្បាប់ដោយផ្អែកលើ**ពូជសាសន៍ ពណ៌សម្បុរ អាយុ ភេទ ជនជាតិភាគតិច ទំនោរផ្លូវភេទ អត្តសញ្ញាណយេនឌ័រ ឬការបញ្ចេញមតិ សាសនា ជំនឿ ដើមកំណើតជាតិ ពិការភាព ស្ថានភាពអតីតយុទ្ធជន (រួមទាំងអតីតយុទ្ធជនសម័យសង្គ្រាមវៀតណាម)** ឬសាវតា។

MassDEP អនុលោមតាមច្បាប់ស្តីពីគ្រឹះស្ថានសាធារណៈរបស់រដ្ឋត្រង់ប្រការ G.L. c. 272 §§ 92A, 98, 98A ដែលហាមឃាត់ការបែងចែក ការរើសអើង ឬការដាក់កម្រិតលើការទទួលយក ឬការព្យាបាលនៅកន្លែងគ្រឹះស្ថានសាធារណៈដោយផ្អែកលើ**ពូជសាសន៍ ពណ៌សម្បុរ ជំនឿសាសនា ដើមកំណើតជាតិ ភេទ អត្តសញ្ញាណយេនឌ័រ ទំនោរផ្លូវភេទ ថ្នង់ ពិការភ្នែក ឬពិការផ្លូវកាយ ឬបញ្ញា ឬពូជវង្សជីដូនជីតា។**

ដើម្បីស្នើសុំព័ត៌មានបន្ថែមអំពីសេចក្តីជូនដំណឹងនេះ ឬដាក់ពាក្យបណ្តឹងក្រោមចំណងជើង VI ឬច្បាប់ផ្សេងទៀតស្តីពីការមិនការរើសអើង សូមទាក់ទង៖

Michelle Waters-Ekanem, អ្នកសម្របសម្រួលផ្នែកមិនរើសអើង MassDEP – ការិយាល័យផ្នែកចម្រុះ និងសិទ្ធិស៊ីវិល
One Winter Street,ជាន់ទីបី
Boston, MA 02108
ទូរសព្ទ៖ 617 292-5751
អ៊ីមែល៖ michelle.waters-ekanem@state.ma.us

---

[1] ច្បាប់សហព័ន្ធតម្រូវឱ្យមានការអនុលោមដោយទីភ្នាក់ងាររដ្ឋដែលទទួលបានមូលនិធិសហព័ន្ធក្រោមលក្ខន្តិកៈបន្ថែមទាំងនេះស្តីពីការមិនការរើសអើង៖ ផ្នែកទី 504 នៃច្បាប់ស្តារនីតិសម្បទាឆ្នាំ 1973 ច្បាប់ស្តីពីការរើសអើងអាយុឆ្នាំ 1975 ចំណងជើង IX នៃវិសោធនកម្មច្បាប់អប់រំឆ្នាំ 1972 និងផ្នែកទី 13 នៃវិសោធនកម្មច្បាប់របស់សហព័ន្ធស្តីពីការគ្រប់គ្រងការបំពុលទឹក ឆ្នាំ 1972 ។ ទីភ្នាក់ងារការពារបរិស្ថានសហរដ្ឋអាមេរិក (EPA) បានដាក់បញ្ចូលនូវលក្ខខណ្ឌមិនរើសអើងសហព័ន្ធទៅក្នុងបទប្បញ្ញត្តិរបស់ខ្លួនដែលអាចរកឃើញក្នុងផ្នែក 40 CFR ទី 5 និងទី 7។